ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦០ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីពិនិត្យផ្លូវច្បាប់ លើកិច្ចព្រមព្រៀងដែលកំពុងអនុវត្ត ដើម្បីរៀបចំកិច្ចព្រមព្រៀងថ្មី សម្រាប់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១._**

ត្រូវបានបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីពិនិត្យផ្លូវច្បាប់លើកិច្ចព្រមព្រៀងដែលកំពុងអនុវត្ត ដើម្បីរៀបចំកិច្ចព្រមព្រៀងថ្មីសម្រាប់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងខេត្តព្រះសីហនុ ហៅកាត់ថា "គណៈកម្មាធិការអន្តរក្រសួង" ដែលមានសមាសភាព ដូចខាងក្រោម៖

- ពិនិត្យនិងចរចាជាមួយក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (SCA) និងក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានកម្ពុជា (CAIC) ដើម្បីរៀបចំកិច្ចព្រមព្រៀងសហប្រតិបត្តិការវិនិយោគលើអាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី និងបិទអាកាសយានដ្ឋានអន្តរជាតិភ្នំពេញបច្ចុប្បន្ន។
- ពិនិត្យនិងចរចាជាមួយក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (SCA) ដើម្បីរៀបចំកិច្ចព្រមព្រៀងថ្មីសម្រាប់អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ដោយដាក់បញ្ចូលនូវគម្រោងផែនការនិងពេលវេលាអភិវឌ្ឍថ្មី។
- ធ្វើរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ អំពីវឌ្ឍនភាពក្នុងការពិនិត្យនិងរៀបចំកិច្ចព្រមព្រៀងថ្មីសម្រាប់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុជូន ប្រមុខរាជរដ្ឋាភិបាល ដើម្បីពិនិត្យសម្រេចនិងផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់។
- អនុវត្តភារៈកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ ៣._**

គណៈកម្មាធិការអន្តរក្រសួង មានសិទ្ធបង្កើតអនុគណៈកម្មាធិការឬក្រុមការងារមួយចំនួនតាមការចាំបាច់ ដោយសេចក្តីសម្រេចរបស់ប្រធាន។

**ប្រការ ៤._**

គណៈកម្មាធិការអន្តរក្រសួង មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ ៥._**

គណៈកម្មាធិការអន្តរក្រសួង អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងអ្នកជំនាញ ដើម្បីពិគ្រោះយោបល់ ឬចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬចូលរួមក្នុងការសិក្សាស្រាវជ្រាវ និងផ្តល់យោបល់តាមការចាំបាច់។

**ប្រការ ៦._**

គណៈកម្មាធិការអន្តរក្រសួង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានតាមការប្រគល់សិទ្ធិរបស់ប្រធាន។

**ប្រការ ៧._**

ប្រភពថវិកាចំណាយរបស់គណៈកម្មាធិការអន្តរក្រសួង គឺបានមកពីប្រភព៖

- ថវិកាជាតិក្នុងគម្រោងចំណាយរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ការឧបត្ថម្ភពីក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (SCA) ក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានកម្ពុជា (CAIC) និងក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានអន្តរជាតិសៀមរាប-អង្គរ (AIAI)។

**ប្រការ ៨._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

| | | |
|---|---|---|
| ១. ឯកឧត្តម **ជា សុផារ៉ា** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២. ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធានប្រចាំការ |
| ៣. ឯកឧត្តម **សាយ សំអាល់** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| ៤. ឯកឧត្តម **កើត រិទ្ធ** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៥. ឯកឧត្តម **ទី តាយី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦. ឯកឧត្តម **សុខ ខាវ៉ាន់** | រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ៧. ឯកឧត្តម **សយ សុខាន់** | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ៨. ឯកឧត្តម **លី រស្មី** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៩. ឯកឧត្តម **ហូ លីហួច** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១០. ឯកឧត្តម **ពេជ អន្ត** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ទីស្តីគណៈរដ្ឋមន្ត្រី | សមាជិក |
| ១១. ឯកឧត្តម **ហាក់ សុខហេង** | សមាជិកនិងជាអគ្គលេខាធិការរងក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១២. ឯកឧត្តម **ព្រូ ស៊ីថន** | ទីប្រឹក្សារដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៣. ឯកឧត្តម **ឃួង ស្រេង** | អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |
| ១៤. ឯកឧត្តម **គួច ចំរើន** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |
| ១៥. ឯកឧត្តម **ទៀ សីហា** | អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ១៦. ឯកឧត្តម **សារិន គុណ្ណាករ** | អគ្គនាយកបច្ចេកទេស នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក/លេខាធិការ |
| ១៧. ឯកឧត្តម **សៅ ចន្ទ្រនា** | នាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ | សមាជិក |
| ១៨. ឯកឧត្តម **ម៉ឺន រដ្ឋា** | នាយកអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប | សមាជិក |
| ១៩. ឯកឧត្តម **វ៉ាន់ ណូរ៉ាក់** | នាយកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ | សមាជិក |
| ២០. លោកបណ្ឌិត **សរ សិនិរ៉ា** | ប្រធាននាយកដ្ឋាននីតិកម្មនិងច្បាប់វិនិយោគ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២១. លោក **ឡុង ហៃគំពូល** | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងនីតិកម្ម នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | លេខាធិការ |

**ប្រការ ២.**_

គណៈកម្មាធិការអន្តរក្រសួងមានភារៈកិច្ច ដូចខាងក្រោម៖

- ពិនិត្យនិងសិក្សាកិច្ចព្រមព្រៀងសម្បទាន ដែលមានស្រាប់ទាំងអស់ពាក់ព័ន្ធនឹងការវិនិយោគអាកាសយានដ្ឋានអន្តរជាតិនៅភ្នំពេញនិងខេត្តព្រះសីហនុ រវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (SCA) និងជាមួយក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានកម្ពុជា (CAIC) ដើម្បីរៀបចំកិច្ចព្រមព្រៀងថ្មី។
- ពិនិត្យបញ្ចប់កិច្ចព្រមព្រៀង រវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (SCA) ដើម្បីដំណើរការក្រុមហ៊ុនវិនិយោគថ្មី(AIAI)។

- ពិនិត្យនិងចរចាជាមួយក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (SCA) និងក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានកម្ពុជា (CAIC) ដើម្បីរៀបចំកិច្ចព្រមព្រៀងសហប្រតិបត្តិការវិនិយោគលើអាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី និងបិទអាកាសយានដ្ឋានអន្តរជាតិភ្នំពេញបច្ចុប្បន្ន។
- ពិនិត្យនិងចរចាជាមួយក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (SCA) ដើម្បីរៀបចំកិច្ចព្រមព្រៀងថ្មីសម្រាប់អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ដោយដាក់បញ្ចូលនូវគម្រោងផែនការនិងពេលវេលាអភិវឌ្ឍថ្មី។
- ធ្វើរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ អំពីវឌ្ឍនភាពក្នុងការពិនិត្យនិងរៀបចំកិច្ចព្រមព្រៀងថ្មីសម្រាប់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុជូន ប្រមុខរាជរដ្ឋាភិបាល ដើម្បីពិនិត្យសម្រេចនិងផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់។
- អនុវត្តភារៈកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ ៣._**

គណៈកម្មាធិការអន្តរក្រសួង មានសិទ្ធបង្កើតអនុគណៈកម្មាធិការឬក្រុមការងារមួយចំនួនតាមការចាំបាច់ ដោយសេចក្តីសម្រេចរបស់ប្រធាន។

**ប្រការ ៤._**

គណៈកម្មាធិការអន្តរក្រសួង មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ ៥._**

គណៈកម្មាធិការអន្តរក្រសួង អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងអ្នកជំនាញ ដើម្បីពិគ្រោះយោបល់ ឬចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬចូលរួមក្នុងការសិក្សាស្រាវជ្រាវ និងផ្តល់យោបល់តាមការចាំបាច់។

**ប្រការ ៦._**

គណៈកម្មាធិការអន្តរក្រសួង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានតាមការប្រគល់សិទ្ធិរបស់ប្រធាន។

**ប្រការ ៧._**

ប្រភពថវិកាចំណាយរបស់គណៈកម្មាធិការអន្តរក្រសួង គឺបានមកពីប្រភព៖

- ថវិកាជាតិក្នុងគម្រោងចំណាយរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ការឧបត្ថម្ភពីក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (SCA) ក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានកម្ពុជា (CAIC) និងក្រុមហ៊ុនវិនិយោគអាកាសយានដ្ឋានអន្តរជាតិសៀមរាប-អង្គរ (AIAI)។

**ប្រការ ៨._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារៈកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១២កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ